# សេចក្តីថ្លែងការណ៍របស់ដៃគូអភិវឌ្ឍន៍

## របៀបវារៈទី IIIA: កំណែទម្រង់ការអភិវឌ្ឍន៍បែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

## ថ្លែងដោយ លោក រ៉ាហ្វាអែល ដូចាវ ម៉ូរ៉េណូ (Rafael Dochao Moreno) ភារៈធារីនៃគណៈប្រតិភូសហភាពអឺរ៉ុប

## តំណាងឱ្យដៃគូអភិវឌ្ឍន៍នៅក្នុងវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣

## ភ្នំពេញ ថ្ងៃទី ២ មិថុនា ២០១០

*សូមគោរពឯកឧត្តម* ***គាត ឈន់*** *ឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

*សូមគោរពឯកឧត្តម* ***ស ខេង*** *ឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ*

*ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីគោរពរាប់អាន!*

តាងនាមឱ្យដៃគូអភិវឌ្ឍន៍នៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំមានកិត្តិយសសូមធ្វើសេចក្តីថ្លែងការណ៍ ស្តីពីការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ជូនចំពោះរាជរដ្ឋាភិបាលកម្ពុជា ។

ជាបឋម ខ្ញុំសូមចែករំលែកនូវការកត់សំគាល់មួយចំនួន ស្តីពីការរីកចំរើននៃការងារកំណែទម្រង់ ការអភិវឌ្ឍន៍បែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។ បន្ទាប់មកខ្ញុំសូមផ្តោតទៅលើផ្នែកគោលនយោបាយ - បើយោងទៅតាមទស្សនៈវិស័យរបស់ដៃគូអភិវឌ្ឍន៍ - ផ្នែកនេះទាមទារឱ្យមានការរីកចំរើនទៅមុខជាលក្ខណៈបន្ទាន់ ។

### ១. បរិបទ និងការរីកចំរើនថ្មីៗក្នុងការងារកំណែទម្រង់ការអភិវឌ្ឍបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

ដៃគូអភិវឌ្ឍន៍សូមសំដែងនូវសេចក្តីអបអរសាទរចំពោះការរីកចំរើនគួរអោយកត់សំគាល់ដែលសំរេចបានដោយរាជរដ្ឋាភិបាលកម្ពុជានៅក្នុងការអនុវត្តន៍ការងារកំណែទម្រង់ការអភិវឌ្ឍន៍បែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ចាប់តាំងពីការបង្កើត និងរៀបចំឱ្យសំរេចបាននូវច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ។ សមិទ្ធិផលជាច្រើនបានសំរេច ចាប់តាំងពីសម័យប្រជុំចុងក្រោយនាខែ ធ្នូ ឆ្នាំ ២០០៨ កន្លងមក ។

កម្មវិធីជាតិសំរាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរយៈពេល១០ឆ្នាំ ត្រូវបានបញ្ចប់ និង អនុម័ត។ ផែនការអនុវត្តន៍រយៈពេល៣ឆ្នាំ កំពុងត្រូវបានរៀបចំ។ កិច្ចព្រមព្រៀងរួមគ្នាមួយ ស្តីពីអភិក្រម ដែលផ្តោតលើកម្មវិធី ក្នុងការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវបានសំរេចឡើង ។ ក្រោយពី មានការបោះឆ្នោត នៅខែឧសភា ឆ្នាំ២០០៩ ក្រុមប្រឹក្សារដ្ឋបាលនៅថ្នាក់ក្រោមជាតិ ត្រូវបានបង្កើតឡើង។ លិខិតបទដ្ឋាននានាជាច្រើន ត្រូវបានអនុម័ត ដើម្បីជំរុញដល់ការអនុវត្តន៍លើទិដ្ឋភាពផ្សេងៗនៃកំណែទម្រង់នេះ។

ចំណុចទាំងអស់នេះ បានរួមចំណែកបង្កើតជាគ្រឹះដ៏រឹងមាំ សំរាប់កសាងការងារកំណែទម្រង់ ដែលមានគោលបំណង ពង្រឹងគណនេយ្យភាពតាមបែបប្រជាធិបយេត្យ ជំរុញការអភិវឌ្ឍន៍មូលដ្ឋាន និងធ្វើឱ្យសម្រេចបាននូវការកាត់បន្ថយភាពក្រីក្រដែលមានលក្ខណៈចិរភាព នៅទូទាំងប្រទេសកម្ពុជា។

**កម្មវិធីជាតិ និងផែនការអនុវត្តន៍រយៈពេល ៣ ឆ្នាំ**

ដៃគូអភិវឌ្ឍន៍សូមឆ្លៀតឱកាសនេះ សម្តែងនូវសេចក្តីកោតសរសើរចំពោះរាជរដ្ឋាភិបាលកម្ពុជា ក្នុងការរៀបចំកម្មវិធីជាតិរយៈពេល១០ឆ្នាំ។ ការរៀបចំកម្មវិធីជាតិត្រូវបានបញ្ចប់ ដោយមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយ ហើយឥឡូវនេះ ត្រូវបានអនុម័តដោយគណៈកម្មាធិការជាតិសំរាប់ការអភិវឌ្ឍតាមបែបប្រជាធិតេយ្យនៅថ្នាក់ក្រោមជាតិ និងទីស្តីការគណៈមន្ត្រី។

ដូចដែលបានឆ្លុះបញ្ចាំងនៅក្នុងសូចនាករតាមដានត្រួតពិនិត្យរួមគ្នាថ្មី (JMI) បញ្ហាប្រឈមនៅចំពោះមុខ គឺត្រូវធ្វើដំណើរចេញពីផែនការ ដោយប្រែក្លាយវាឱ្យទៅជាសកម្មភាពជាក់ស្តែង។ យើងទទួលស្គាល់ថា កម្មវិធីជាតិបានដាក់ចេញជាកំណែទម្រង់ដែលមានរយៈពេល១០ឆ្នាំ ប៉ុន្តែយើងក៏ត្រូវទទួលស្គាល់ផងដែរថា ការធ្វើឱ្យមានការរីកចំរើនឆាប់រហ័ស ក៏ជាកត្តាដ៏សំខាន់ណាស់ដែរ សំរាប់ធានានូវកំលាំងចលករនៃការងារកំណែទម្រង់។ វាជារឿងសំខាន់ណាស់ដែលថា សំរាប់ជំហានបន្ទាប់ ត្រូវតែមានការចូលរួមពីផ្នែករដ្ឋាភិបាលទាំងអស់ ហើយដែលត្រូវធ្វើឡើង តាមរយៈការសម្របសម្រួលដ៏ល្អមួយ។ ផែនការអនុវត្តន៍រយៈពេល៣ឆ្នាំ ត្រូវយកមកប្រើប្រាស់ជាគំរូដំបូងគេ ក្នុងការប្រែក្លាយ

កម្មវិធីជាតិសំរាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ឱ្យទៅជាសកម្មភាពជាក់ស្តែង។ យើងកំពុងរង់ចាំ ការបង្កើតផែនការអនុវត្តន៍នេះ និងការដាក់វាឱ្យចូលជាធរមាន។

**ការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ចំពោះអភិក្រមដែលផ្តោតលើកម្មវិធី (PBA)**

របាយការណ៍ស្តីពីការផ្តល់ជំនួយប្រកបដោយប្រសិទ្ធភាពដល់ប្រទេសកម្ពុជាឆ្នាំ២០១០បានគូសបញ្ជាក់ថា អភិក្រមដែលផ្តោតលើកម្មវិធី គឺជាមធ្យោបាយដែលរាជរដ្ឋាភិបាលពេញចិត្តបំផុត ដើម្បីពង្រឹងភាពជាម្ចាស់ ការលើកកំពស់ការអភិវឌ្ឍន៍សមត្ថភាពឱ្យកាន់តែមានលក្ខណៈស៊ីសង្វាក់និងមាននិរន្តរភាព និងការបញ្ចូលនូវធនធានទាំងឡាយទៅក្នុងផែនការយុទ្ធសាស្ត្រវិស័យមួយដែលមានលក្ខណៈទូលំទូលាយ និងមានរយៈពេលមធ្យមដែលស្របគ្នាជាមួយនឹងគោលដៅអភិវឌ្ឍន៍ជាតិ[១] ។

ជាមួយនឹងគោលបំណងរួមនៃអភិបាលកិច្ចល្អនៅមូលដ្ឋាន និងការអភិវឌ្ឍន៍មូលដ្ឋានប្រកបដោយនិរន្តរភាព ដៃគូអភិវឌ្ឍន៍នឹងធ្វើការជាមួយគ្នាដើម្បីគាំទ្រកម្មវិធីជាតិសំរាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្នុងការកសាងសមត្ថភាពនៃស្ថាប័ន គាំទ្រការបង្កើតគោលនយោបាយ ក្របខ័ណ្ឌគតិយុត្តិ ដែលកំណត់និងធ្វើឱ្យដំណើរការកំណែទម្រង់វិមជ្ឈការប្រព្រឹត្តទៅបាន។

ដៃគូអភិវឌ្ឍន៍គាំទ្រយ៉ាងពេញទំហឹងចំពោះអភិក្រមដែលផ្តោតលើកម្មវិធី នៅក្នុងដំណើរការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ហើយនឹងធ្វើការរួមគ្នាឆ្ពោះទៅកាន់គោលដៅនេះ។ យើងនឹងគាំទ្ររាជរដ្ឋាភិបាលក្នុងការបង្កើតអភិក្រមដែលផ្តោតលើកម្មវិធីដោយផ្អែកលើភាពជឿទុកចិត្តគ្នា និងភាពស្របគ្នានៃទស្សនៈ តម្លៃ និងសកម្មភាព។

## ២. បញ្ហាសំខាន់ៗ

[1] របាយការណ៍ស្តីពីការផ្តល់ជំនួយប្រកបដោយប្រសិទ្ធភាពដល់ប្រទេសកម្ពុជា ឆ្នាំ ២០១០។ រៀបរៀងដោយក្រុមប្រឹក្សាកម្ពុជាដើម្បីការអភិវឌ្ឍន៍ និងការស្តារនិតិសម្បទា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សំរាប់វេទិការ នៃកិច្ចសហប្រតិបត្តិការ ដើម្បីការអភិវឌ្ឍន៍កម្ពុជា លើកទី ៣ (CDCF)។ សេចក្តីព្រាង ថ្ងៃអង្គារ៍ ទី ២០ មេសា ២០១០

*ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី*

ដៃគូអភិវឌ្ឍន៍សូមសាទរនូវស្មារតីរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានថ្លែងថា "....កំណែទម្រង់ គឺជាកត្តាស្លាប់រស់សំរាប់កម្ពុជា។ នៅក្នុងន័យនេះ កម្ពុជាមិនមានជំរើសផ្សេងទៀត ក្រៅពីបន្តការអនុវត្តន៍រាល់កម្មវិធីកំណែទម្រង់ដែលចាំបាច់ ដោយជំហររឹងមាំ និងប្រកបដោយមនះសិការ...[២] ។"

ដៃគូអភិវឌ្ឍន៍សូមគូសបញ្ជាក់បញ្ហាមួយចំនួនដែលលេចឡើង ហើយមានសារៈសំខាន់ក្នុងការធានាដើម្បីឱ្យកំណែទម្រង់ការងារអភិវឌ្ឍន៍បែបប្រជាធិបតេយ្យបោះជំហានទៅមុខ ហើយការឈានទៅមុខនេះ ក៏ត្រូវស្ថិតនៅក្នុងស្មារតីនៃរដ្ឋធម្មនុញ្ញកម្ពុជា និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ។

## ***១- ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវបានពង្រឹងតាមបណ្តាវិស័យ និងក្រសួងស្ថាប័នពាក់ព័ន្ធ***

"រាជរដ្ឋាភិបាលរំពឹងទុកថាក្រសួងនិមួយៗ នឹងខិតខំប្រឹងប្រែងឱ្យអស់ពីសមត្ថភាព ដើម្បីភ្ជាប់ខ្លួនទៅនឹងគោលនយោបាយនៃវិមជ្ឈការនិងវិសហមជ្ឈការ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ហើយប្រព្រឹត្តិតាមដោយភាពទទួលខុសត្រូវខ្ពស់ក្នុងការ អនុវត្តន៍គោលនយោបាយ និងច្បាប់នេះ "[៣]។ ទោះបីនេះគឺជាចំណុចដ៏សំខាន់នៃរបៀបវារៈ របស់កំណែទម្រង់ក៏ដោយ ភាពរីកចំរើនទាក់ទងទៅនឹងការចូលរួមនៃបណ្តាក្រសួងនិងស្ថាបន័ មានកំរិតមិនទាន់សមល្មមនៅឡើយ : ត្រូវការឱ្យ មានសកម្មភាពតាមវិស័យនានាជាបន្ទាន់ ។

---

[២] ថ្លែងដោយសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ស្តីពី "យុទ្ធសាស្ត្រចតុកោណ" ដើម្បីការរីកចំរើនលូតលាស់ ការងារ សមធម៌ និងប្រសិទ្ធភាព តំណាក់កាលទី ២។ នៅក្នុងឱកាសនៃកិច្ចប្រជុំជាន់ខ្ពស់រដ្ឋសភាជាតិ និតិកាលទី ៤ ភ្នំពេញ ថ្ងៃទី ២៦ កញ្ញា ២០០៨

[៣] ចំណុចសំខាន់នៃកំណត់ហេតុ — ថ្លែងក្នុងពិធីផ្សព្វផ្សាយស្តីពី កិច្ចដំណើរការនៃការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្តក្រុង ស្រុក ខ័ណ្ឌ — នាសាលសន្និសិទចតុមុខ ថ្ងៃទី ២៨ មករា ២០០៩

នៅជ្រុងម្ខាង កិច្ចខំប្រឹងប្រែងរបស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្នុងការប្រាស្រយ័ទាក់ទងជាមួយបណ្ដាក្រសួងពាក់ព័ន្ធ អំពីគោលបំណងនិងសារៈសំខាន់នៃកំណែទម្រង់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវតែបង្កើនឱ្យបានខ្លាំងក្លាជាងមុននិងស៊ីជម្រៅថែមទៀត។ វាជាការបន្ទាន់ផងដែរ ***ក្នុងការរៀបចំ និងឯកភាពគ្នាលើយុទ្ធសាស្ត្រសំរាប់ការកំណត់ និងផ្ទេរមុខងារ*** ពីរដ្ឋាភិបាលថ្នាក់ជាតិទៅអាជ្ញាធរថ្នាក់ក្រោមជាតិ ។

នៅជ្រុងម្ខាងទៀត ដៃគូរអភិវឌ្ឍន៏បានប្ដេជ្ញាក្នុងការធ្វើការងារជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជាដើម្បីធានាថា ***ក្រុមការងារបច្ចេកទេសនិមួយៗ នឹងត្រូវបានប្រមូលផ្តុំគ្នា នឹងទទួលរ៉ាប់រងធ្វើកិច្ចការចាំបាច់ដែលត្រូវដោយវិស័យនិមួយៗ ដើម្បីឱ្យរបៀបវារៈនៃកំណែទំរង់ ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បោះជំហានទៅមុខ។*** ចំពោះភាគីយើង យើងទទួលស្គាល់ភាពចាំបាច់ និងសារៈសំខាន់ក្នុងការសម្របការគាំទ្ររបស់យើងទៅលើការងារលើវិស័យនានា (សុខភាព អប់រំ ។ល។) នាពេលបច្ចុប្បន្ន និងពេលអនាគត ទៅក្នុងដំណើរការកំណែទំរង់ ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

### ***២, ការបែងចែកធនធាន ទៅអាជ្ញាធរថ្នាក់ក្រោមជាតិ***

ការធ្វើវិមជ្ឈការនៃការទទួលខុសត្រូវថ្មី និងការទទួលខុសត្រូវបន្ថែមផ្សេងៗទៀត ទៅអោយអាជ្ញាធរថ្នាក់ក្រោមជាតិ ទាមទារនូវធនធានបុគ្គលិក និងហិរញ្ញវត្ថុសមស្រប ដែលអាចប្រមើលទុកជាមុនបាន ។ ធនធានទាំងនេះត្រូវការជាចាំបាច់ ដើម្បីចាប់ផ្ដើមដំណើរការ និងធានានិរន្តរភាពនៃការងារទាំងនេះ។

ដើម្បីអាចនឹងសម្របការគាំទ្រឱ្យបានពេញលេញ ដល់ផែនការរបស់រាជរដ្ឋាភិបាលស្ដីពីបញ្ហាសំខាន់ៗទាក់ទងនឹងហិរញ្ញប្បទាន ដៃគូអភិវឌ្ឍន៏ស្វែងរកនូវការពង្រឹងកិច្ចសន្ទនាជាមួយគណៈកម្មាធិការជាតិដឹកនាំការងារកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើ***ទំរង់បែបបទ និងតារាងពេលវេលាសំរាប់ប្រមើលទុក ហើយបើសមស្រប រួមទាំងហិរញ្ញប្បទានដែលមិនកំណត់លក្ខខ័ណ្ឌ សំរាប់អាជ្ញាធរថ្នាក់ក្រោមជាតិ*** ។ ដៃគូរអភិវឌ្ឍន៏ សូមស្វាគមន៏ចំពោះការធ្វើបច្ចុប្បន្នភាពនៃភាពរីកចំរើនក្នុងផ្នែកដ៏សំខាន់នេះ។

ចំពោះសំនួរដែលពាក់ព័ន្ធនឹងធនធានមនុស្ស ដៃគូរអភិវឌ្ឍន៍ស្វែងរកកិច្ចសន្ទនាបន្ថែមទៀតជាមួយក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលលើបញ្ហាដែលថា តើមន្ត្រីរាជការអាចផ្ទេរទៅ ឬដាក់អោយបំរើការងារនៅ អាជ្ញាធរថ្នាក់ក្រោមជាតិយ៉ាងដូចម្តេច ។

ពាក់ពន្ធ័ទៅនឹងតួនាទីនាពេលអនាគតរបស់អាជ្ញាធរថ្នាក់ក្រោមជាតិ ដៃគូរអភិវឌ្ឍន៍សូមសំដែងនូវការរំពឹងទុកថារដ្ឋាភិបាលនឹងបន្តការផ្តោតការយកចិត្តទុកដាក់ដល់កំណែទំរង់នេះ ជំរុញការពង្រឹងសិទ្ធិ និងអំណាចក្នុងការធ្វើសេចក្តីសំរេចរបស់ក្រុមប្រឹក្សា ជាពិសេសចំពោះក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលជាតំណាងត្រូវបានបោះឆ្នោតដោយផ្ទាល់ពីប្រជាពលរដ្ឋ ។

### *៣, អន្តរទំនាក់ទំនងរវាងរបៀបវារៈកំណែទំរង់វិស័យសាធារណៈទាំងបី*

ដូចដែលយើងទាំងអស់គ្នាបានដឹងហើយថា រាជរដ្ឋាភិបាលកំពុងធ្វើកំណែទំរង់បីនៅក្រោមឆ័ត្រនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទីពីរក្នុងពេលជាមួយគ្នា ។ កំណែទំរង់និមួយៗនៃកំណែទំរង់ដ៏ធំទាំងបីនេះ ដែលរួមមានៈ ការអភិវឌ្ឍន៍តាមបែបប្រជាធិតេយ្យនៅថ្នាក់ក្រោមជាតិ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទំរង់រដ្ឋបាលសាធារណៈ បានកំណត់ការផ្លាស់ប្តូរចំបងៗ ក្នុងជួររាជរដ្ឋាភិបាលទាំងមូល។ កំណែទំរង់ទាំងនេះមានលក្ខណៈពឹងផ្អែកគ្នាទៅវិញទៅមកនៅក្នុងន័យថា ជោគជ័យក្នុងកំណែទំរង់ណាមួយ ក្នុងចំណោមកំណែទំរង់ទាំងនេះ ជះឥទ្ធិពលដល់ភាពរីកចំរើនក្នុងកំណែទំរង់ដទៃទៀត។

ដៃគូរអភិវឌ្ឍន៍សូមកោតសសើរនឹងវាយតំលៃខ្ពស់ចំពោះ ***សេចក្តីថ្លែងការដ៏ច្បាស់លាស់ របស់រាជរដ្ឋាភិបាលស្តីពីយុទ្ធសាស្ត្រចំបងដើម្បីអនុវត្តន៍កំណែទំរង់ទាំងបីនេះក្នុងបែបផែនសម្រេបសម្រួលមួយ*** និងចំពោះការរំពឹងទុកពី តួនាទីដែលត្រូវបំពេញដោយជំនួយអភិវឌ្ឍន៍ នៅក្នុងយុទ្ធសាស្ត្រដ៏ចំបងនេះ។

ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី

ជាសេចក្តីសន្និដ្ឋាន យើងដែលជាដៃគូរអភិវឌ្ឍន៍បានប្តេជ្ញាចិត្តក្នុងការធ្វើការជាមួយរាជរដ្ឋាភិបាលកម្ពុជាដើម្បីធានាការរីកចំរើនក្នុងកំណែទំរង់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលយើងចាត់ទុកថា

ជាការដ៏សំខាន់ចំពោះ អភិបាលកិច្ចល្អ និងការអភិវឌ្ឍន៍មូលដ្ឋាននៅកម្ពុជា។ យើងប្តេជ្ញាចិត្តក្នុងការសម្របសម្រួលការងារជាបន្តទៀត ទាក់ទងទៅនឹងដំណើរការកំណែទម្រង់ការអភិវឌ្ឍន៍តាមបែបប្រជាធិតេយ្យនៅថ្នាក់ក្រោមជាតិ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង កំណែទំរង់រដ្ឋបាលសាធារណៈ ដើម្បីពង្រឹងភាពជាដៃគូររបស់យើងជុំវិញអភិក្រមដែលផ្តោតលើកម្មវិធី ដើម្បីជួយគាំទ្រដល់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងជួយគាំទ្រដល់ការប្រគល់មុខងារ និងធនធានដល់ អាជ្ញាធរថ្នាក់ក្រោមជាតិ ។

**សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់ របស់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី។**